សារសំខាន់របស់ជី

ដំណាំដុះលូតលាស់ល្អ នឹងធ្វើឱ្យទិន្នផលកើនឡើង

តើសារធាតុចិញ្ចឹមមានតួនាទីយ៉ាងណាខ្លះចំពោះការលូតលាស់របស់រុក្ខជាតិ?

តួនាទីរបស់ធាតុអាសូត (N)	តួនាទីរបស់ធាតុផូស្វ័រ (P)	តួនាទីរបស់ធាតុប៉ូតាស្យូម (K)
-ជួយស្លឹកឱ្យមានពណ៌បៃតងក្រម៉ៅ -ជំរុញការលូតលាស់ -ជួយឱ្យមានការបែកគុម្ព	-ជួយឱ្យឫសដុះលូតលាស់បានល្អ -ជំរុញឱ្យឆាប់ចេញផ្កា និងការទុំ -បង្កើនគុណភាពគ្រាប់	-ជួយឱ្យរុក្ខជាតិមានភាពធន់ទ្រាំទៅនឹងលក្ខខណ្ឌអាកាសធាតុមិនល្អ -ជំរុញការបែកគុម្ព -បង្កើនទំហំ និងទំងន់គ្រាប់

ចំពោះដំណាំស្រូវ តើសញ្ញាណាខ្លះដែលបង្ហាញពីការខ្វះសារធាតុចិញ្ចឹម?

កង្វះធាតុអាសូត

តួស្លឹកមានទំហំតូច ប្រវែងស្លឹកខ្លី ដុះត្រង់ទៅលើ និងស្លឹកឡើងពណ៌លឿង ។

កង្វះធាតុផូស្វ័រ

ដើមស្រូវតូចរាវមិនរឹងមាំ ស្លឹកខ្លីមានពណ៌បៃតងក្រម៉ៅ ដុះត្រង់ទៅលើ ស្លឹកចាស់មានពណ៌លឿងឬក្រហមស្វាយ ។

កង្វះធាតុប៉ូតាស្យូម



ចុងស្លឹកមានពណ៌លឿងត្នោត ដើមស្រូវមានសភាពតឿ ស្លឹកមានទំហំតូច ខ្លី និងមានដើមតូចរាវ ។

ចំពោះដំណាំផ្សេងៗ តើសញ្ញាណាខ្លះដែលបង្ហាញពីការខ្វះសារធាតុចិញ្ចឹម?

កង្វះធាតុអាសូត

(ប៉ោងប៉ោះ)

(ស្លឹកពោត)

ស្លឹកនៅផ្នែកខាងក្រោមឡើងពណ៌លឿង ចាប់ពីចុងតួស្លឹកមកមុន ។

កង្វះធាតុផូស្វ័រ

(ស្ពៃ)

(ពោត)

ស្លឹកប្រែពណ៌ទៅជាពណ៌ស្វាយ ដោយចាប់ផ្តើមពីជាយស្លឹក ។

កង្វះធាតុប៉ូតាស្យូម

(សណ្តែកស្សែង)

(ពោត)

ជាយស្លឹកចាប់ឡើងពណ៌លឿង និងប្រែទៅជាក្រម៉ៅ ។

តើយើងគួរប្រើជីមួយណា?

សូមជ្រើសរើសប្រើជីដែលមានសំបកវេចខ្ចប់សរសេរព័ត៌មានជាភាសាខ្មែរ និងមានបញ្ជាក់ពីលេខចុះបញ្ជីកា ឬ ជីដែលមានសំបកវេចខ្ចប់សរសេរ ព័ត៌មានជាភាសាបរទេស តែមានភ្ជាប់ស្លាកដែលបញ្ជាក់ពីលេខចុះបញ្ជីកា និងព័ត៌មានជាភាសាខ្មែរ ពីព្រោះជីទាំងនេះ ត្រូវបានត្រួតពិនិត្យគុណភាពមុននឹងធ្វើការចុះបញ្ជីកា ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

ឧទាហរណ៍ខ្លះៗអំពីលេខបញ្ជីកា ព័ត៌មានជាភាសាខ្មែរ



សំបកវេចខ្ចប់មានព័ត៌មានជាភាសាខ្មែរ និងមានបញ្ជាក់លេខចុះបញ្ជីកា

ឧទាហរណ៍ខ្លះៗអំពីស្លាកដែលបញ្ជាក់ពីលេខបញ្ជីកា

សំបកវេចខ្ចប់មានព័ត៌មានជាភាសាបរទេស តែមានភ្ជាប់ស្លាកដែលបញ្ជាក់ពីលេខចុះបញ្ជីកា និងព័ត៌មានជាភាសាខ្មែរ

សូមប្រឹក្សាយោបល់ជាមួយមន្ត្រីផ្សព្វផ្សាយកសិកម្មប្រចាំនៅមូលដ្ឋានរបស់លោកអ្នក នូវព័ត៌មានលំអិតបន្ថែមផ្សេងៗទៀត ។